**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ**

**និងអតីតយុទ្ធជន**

*រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៩៨*

លេខ: ២៩៨ សកអ

# ប្រកាស

## ស្តីពី

## បដិប្បញ្ញត្តិចំពោះការហាមឃាត់មិន

## ឱ្យប្រើក្មេងធ្វើការពេលយប់

## រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញមាត្រា ១៧៥ នៃច្បាប់ស្តីពីការងារ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស-រកម ០៣៩៧-០១ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាក្សត្រ នៃព្រះរាជា ណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត.១០៩៤-៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត.១០៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាភាពរាជរដ្ឋាភិបាល

- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-១៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើត ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

- បានឃើញអនុក្រឹត្យលេខ ៥៦ អនក្រ-បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

## សំរេច

### ប្រការ ១

ក្មេងដែលមានអាយុពី១៦ឆ្នាំ ទៅក្រោម១៨ឆ្នាំ អាចប្រើឱ្យធ្វើការនៅពេលយប់បាននៅក្នុងរោងចក្រស្លដែក និងដែកថែប រោងចក្រកែវ រោងចក្រក្រដាស រោងចក្រធ្វើស្ករ និងរោងចក្របំបែករ៉ែមាស ដែលត្រូវដើរឥតឈប់ទាំងយប់ទាំងថ្ងៃ។ ការប្រើក្មេងឱ្យធ្វើការពេលយប់នៅក្នុង រោងចក្រទាំងនេះមានគោលបំណងតែម្យ៉ាងគឺ ដើម្បីផ្តល់ការហ្វឹកហ្វឺន ឬបណ្តុះបណ្តាលវិជ្ជាជីវៈដល់ ក្មេងតែប៉ុណ្ណោះ ។

### ប្រការ ២

ក្នុងគ្រប់ករណីទាំងអស់ ថិរវេលាធ្វើការប្រចាំថ្ងៃរបស់ក្មេងមិនអាចលើសពី៨ម៉ោងក្នុងមួយថ្ងៃហើយការសំរាករបស់ក្មេងនៅចន្លោះពីម៉ោងធ្វើការមួយទៅម៉ោងធ្វើការមួយទៀត ត្រូវមានថិរវេលាយ៉ាងហោចណាស់១៣ម៉ោងជាប់គ្នា ។

### ប្រការ ៣

និយោជកដែលចង់ប្រើក្មេងពេលយប់ត្រូវសុំការអនុញ្ញាតជាមុនពីអធិការការងារ។ បន្ទាប់ពីបានទទួលពាក្យស្នើសុំហើយ អធិការការងារត្រូវធ្វើការសំរេចតាមករណីនិមួយៗដោយផ្អែកតាមហេតុនៃការប្រើក្មេង ថិរវេលាធ្វើការ និងការសំរាករបស់ក្មេង ព្រមទាំងវិញ្ញាបនប័ត្រកាយសម្បទារបស់ក្មេង ដែលចេញឱ្យដោយគ្រូពេទ្យការងារផង ។

### ប្រការ ៤

នៅក្នុងគ្រឹស្ថាន សហគ្រាសទាំងអស់ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារនិយោជកអាចប្រើក្មេងប្រុសអាយុពី ១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ឱ្យធ្វើការនៅពេលយប់បានដើម្បីជួយបង្ការគ្រោះថ្នាក់ដែលអាចនឹងកើតមាន ឬដើម្បីជួសជុលគ្រឿងចក្របរិក្ខា ឬសម្ភារៈដែលខូចខាតបណ្តាលមកពីមានគ្រោះថ្នាក់កន្លងមកហើយ។ និយោជកដែលចង់ប្រើក្មេងក្នុងគោលបំណងខាងលើត្រូវជូនដំណឹងឱ្យអធិការការងារបានដឹងជាមុនអំពីហេតុនៃការធ្វើបដិប្បញ្ញត្តិនេះ។

### ប្រការ ៥

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន ៖**

- ព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២ **ស៊ុយ សែម**
- គ្រប់ក្រសួង "ដើម្បីជ្រាប"
- ក្រសួងពត៌មន "ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយ"
- គ្រប់បណ្តាលវិទ្យុ និងទូរទស្សន៍
- រាជកិច្ច
- គ្រប់អធិការដ្ឋានសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ខេត្ត-ក្រុង "ដើម្បីជ្រាប"
- បិទផ្សាយនៅក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន នាយកដ្ឋានអធិការកិច្ចការងារ និងអធិការដ្ឋាន សង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត-ក្រុង
- កាលប្បវត្តិ និងឯកសារ